**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គម**

លេខ : ១៣/២៣ ប.ស.ស.

# សេចក្ដីសម្រេច

# ស្ដីពី

# ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍

## ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្ដីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៧១៣ អនក្រ.តត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.តត ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម
- បានឃើញប្រកាសលេខ១៨៤ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្ដីពីតារកាលិកថែទាំសុខភាព
- បានឃើញប្រកាសលេខ១៦៨ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទានសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. លើកទី១៩ អាណត្តិទី១ នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣

[signature]



អាសយដ្ឋាន អាគារទីស្នាក់ការកណ្ដាល បេឡាជាតិសន្តិសុខសង្គម ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ ០២៣ ៩៩ ៩២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

សេចក្ដីសម្រេចនេះកំណត់អំពីយន្តការ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន ការទាមទារ និងការផ្ដល់តាវកាលិកសម្រាប់គម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ក្នុងគោលដៅសិក្សាសមិទ្ធិលទ្ធភាពនៃការពង្រីកវិសាលភាពសម្រាប់បុគ្គលស្វ័យនិយោជន៍។

**ប្រការ២ .-**

សេចក្ដីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍។

## ជំពូកទី២
## ការចុះបញ្ជី និងបង់ភាគទាន
### ផ្នែកទី១
### ការចុះបញ្ជី

**ប្រការ៣ .-**

បុគ្គលស្វ័យនិយោជន៍ ដែលមានអាយុមិនលើសពី៦០(ហុកសិប)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទស្នើចុះបញ្ជី មានសិទ្ធិចុះបញ្ជីក្នុងគម្រោងសាកល្បងនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តនៅ **ប.ស.ស**។ ការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

**ប្រការ៤ .-**

បុគ្គលស្វ័យនិយោជន៍ ត្រូវបំពេញសលាកប័ត្រព័ត៌មានសមាជិក **ប.ស.ស**។ **ប.ស.ស**. ត្រូវចេញបណ្ណសមាជិកជូនបុគ្គលស្វ័យនិយោជន៍ដែលបានចុះបញ្ជី ដោយអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

បណ្ណសមាជិក **ប.ស.ស**. ត្រូវផ្ដល់ជូនដោយឥតគិតថ្លៃ។ ក្នុងករណីបាត់ឬខូចខាត សមាជិក **ប.ស.ស**. ត្រូវស្នើសុំបណ្ណទុតិយតាយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបាត់ ឬខូចខាត។

ការផ្ដល់បណ្ណទុតិយតានេះ សាមីជនត្រូវបង់ប្រាក់ចំនួន ៥ ០០០(ប្រាំពាន់)រៀល ជូនទៅ **ប.ស.ស**។

បែបបទ និងនីតិវិធីនៃការចុះបញ្ជី ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ផ្នែកទី២
### ការបង់ភាគទាន

**ប្រការ៥ .-**

ភាគទានសម្រាប់គម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ស្មើនឹង ២,៦%(ពីរក្បៀសប្រាំមួយភាគរយ) នៃប្រាក់ចំណូលរបស់សាមីជន។ ប្រាក់ចំណូលជាប់ភាគទានប្រចាំខែ ត្រូវកំណត់ស្មើនឹង ៦០០ ០០០(ប្រាំមួយរយពាន់)រៀល។

ការបង់ភាគទានត្រូវធ្វើឡើងជាប្រចាំខែយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥(ដប់ប្រាំ)នៃខែបន្ទាប់។ ករណីសមាជិកមានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំ ត្រូវស្នើសុំមក **ប.ស.ស.**។ ការបង់ភាគទានប្រចាំឆ្នាំនេះត្រូវធ្វើឡើងនៅខែបន្ទាប់ គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។

ការបង់ភាគទានត្រូវធ្វើដោយផ្ទាល់ឬតាមរយៈប្រព័ន្ធនៃធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារកាណាឌីយ៉ា ក.អ និងធនាគារវឌ្ឍនៈអាស៊ីចំកាត់ ឬតាមរយៈកម្មវិធី NSSFPilotScheme។

## ជំពូកទី៣
## តាវកាលិកផ្នែកថែទាំសុខភាព

**ប្រការ៦ .-**

តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត រួមមានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងប្រាក់បំណាច់មាតុភាព។

**ប្រការ៧ .-**

សមាជិក **ប.ស.ស.** ដែលជាបុគ្គលស្វ័យនិយោជន៍ មានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលដៃគូ **ប.ស.ស.** លុះត្រាតែសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជីជាសមាជិក **ប.ស.ស.**
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នា។

ក្នុងករណីខកខានបង់ភាគទាន សមាជិកមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររយៈពេល២(ពីរ)ខែបន្ថែមទៀត គិតចាប់ពីខែដែលខកខានបង់ភាគទានចុងក្រោយ។

ចំពោះការខកខានបង់ភាគទាន ហើយអស់សុពលភាពប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សមាជិកត្រូវបង់រំលឹកភាគទានទៅតាមចំនួនខែដែលបានខកខាន ដើម្បីមានសិទ្ធិប្រើប្រាស់សេវាឡើងវិញ។ ក្នុងករណីខកខានបង់ភាគទានជាលើកទីពីរ សមាជិកពុំមានសិទ្ធិបង់រំលឹកភាគទានដើម្បីមានសិទ្ធិប្រើប្រាស់សេវាឡើងវិញម្តងទៀតទេ លើកលែងរយៈពេលនៃការចូលរួមក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច ឬករណីប្រធានសក្តិ។

យន្តការបង់រំលឹកភាគទានសម្រាប់បុគ្គលស្វ័យនិយោជន៍ ពុំត្រូវរាប់បញ្ចូលរយៈពេលនៅមានសុពលភាពនៃការចូលរួមក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចឡើយ។

**ប្រការ៨ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

- ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាល
- ការផ្តល់សេវាពិគ្រោះជំងឺក្រៅ
- ការផ្តល់សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល
- ការផ្តល់សេវាព្យាបាលដោយស្នំ ដោយចលនា ឬសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត

- ការផ្តល់សេវាសង្គ្រោះបន្ទាន់។ ក្នុងករណីសង្គ្រោះបន្ទាន់សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** សាមីជនឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក **ប.ស.ស.**
- សេវាបង្ការសុខភាព ដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព។

**ប្រការ៩ .-**

សមាជិក **ប.ស.ស.** ជាស្ត្រីមានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាព លុះត្រាតែបានបង់ភាគទាន៩(ប្រាំបួន)ខែ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយ គិតដល់កាលបរិច្ឆេទសម្រាលកូន។ ប្រាក់បំណាច់មាតុភាព ត្រូវកំណត់ស្មើនឹង ១ ២៦០ ០០០(មួយលានពីររយហុកសិបពាន់)រៀល។ ក្នុងអំឡុងពេលសម្រាកមាតុភាព សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវបន្តបង់ភាគទានមក **ប.ស.ស.**។

**ប្រការ១០ .-**

ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល អាចត្រូវបានផ្តល់ជូនតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ១១ .-**

សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ រួមមានៈ

- ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសម្អាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាលឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាង្គកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែរ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសសៃឈាមបេះដូង
- ការលាងឈាម
- ការពិនិត្យសុខភាពទូទៅ។

សេវាឬការព្យាបាលដូចមានរៀបរាប់ខាងលើនឹងត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់តែប៉ុណ្ណោះ។

**ប្រការ១២ .-**

ជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ដូចខាងក្រោមៈ

- ជំងឺខ្សោយបេះដូង (Cardiac Failure)
- ជំងឺសាច់ដុំបេះដូង (Cardiomyopathy)
- ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)
- ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)
- ជំងឺតម្រងនោមរ៉ាំរ៉ៃ (Chronic renal Disease)
- ជំងឺក្រិនថ្លើម (Cirrhosis of the liver )
- ជំងឺសសៃឈាមក្រហមបេះដូង (Coronary Artery Disease)
- ជំងឺវិបត្តិចង្វាក់បេះដូង ( Dysrhythmias)
- ជំងឺក្រិនសរីរាង្គ ( Multiple Sclerosis)
- ជំងឺវិកលចរិក (Schizophrenia)
- ជំងឺលុយពុស (Systemic Lupus Erythematosus)
- ជំងឺតាឡាសសីមី (Thalassemia)។

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះការប្រើប្រាស់ឱសថព្យាបាលក្រៅពីក្នុងបញ្ជីឱសថសារវន្តគឺជាបន្ទុកចំណាយផ្ទាល់របស់អ្នកជំងឺ វៀលែងតែករណីសង្គ្រោះបន្ទាន់។

ចំពោះឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម មិនមាននៅក្នុងបញ្ជីឱសថសារវន្ត និងការព្យាបាលជំងឺមហារីកដោយសារធាតុគីមី ត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។

**ប្រការ១៣ .-**

ទម្រង់នៃការទាមទារសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ និងប្រាក់បំណាច់មាតុភាព ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សិទ្ធិនៃការទាមទារសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ និងប្រាក់បំណាច់មាតុភាព មានអាជ្ញាយុកាលត្រឹមរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាពឬសម្រាលកូន ឬគិតចាប់ពីកាលបរិច្ឆេទបញ្ចប់គម្រោងសាកល្បងនេះ។

យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**ប្រការ១៤ .-**

មូលនិធិសន្តិសុខសង្គមសម្រាប់ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវរាប់បញ្ចូលក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច។

**ប.ស.ស.** ត្រូវរៀបចំការគ្រប់គ្រងកិច្ចបញ្ជិកាគណនេយ្យដោយឡែកសម្រាប់ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍។

**ប្រការ១៥ .-**

អគ្គនាយក **ប.ស.ស.** ត្រូវរាយការណ៍ពីស្ថានភាពហិរញ្ញវត្ថុនៃការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ជាប្រចាំ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ១៦ .-**

ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវអនុវត្តរយៈពេល១(មួយ)ឆ្នាំ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១៧ .-**

អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធានគ្រប់អង្គភាពនៃ **ប.ស.ស.** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែមាឃមាសា ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២៣

**ជ.ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.**

**ប្រធាន**

អ៊ិត សំហេង

**កន្លែងទទួល:**

- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ